THE SCHOOL DISTRICT OF PHILADELPHIA

**OPERATIONS DIVISION**
440 North Broad Street
Philadelphia, PA 19130

**Oz Hill**
Chief Operating Officer

ថ្ងៃទី ៦ ខែ ធ្នូ ឆ្នាំ ២០២៣

ជូនចំពោះ ក្រុមគ្រួសាររបស់ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ា៖

ខ្ញុំសង្ឃឹមថា លោកអ្នក និងក្រុមគ្រួសាររបស់លោកអ្នកមានសុខភាពល្អ និងមានស្មារតីខ្ពស់នៅពេលលោកអ្នកទទួលលិខិតនេះ។ នៅពេលដែលយើងបន្តដោះស្រាយបញ្ហាដែលបង្កឡើងដោយហានិភ័យបរិស្ថាន ការសង់ ឬជួសជុលអគារ និងកាលៈទេសៈដែលមិនអាចប៉ាន់ស្មាន ឬគ្រោងទុកជាមុនបានផ្សេងៗទៀត ក្រសួងអប់រំនៃទីក្រុងហ្វីឡាដែលហ្វ្យ៉ានៅតែប្តេជ្ញាក្នុងការធានាដល់សុវត្ថិភាព និងសុខុមាលភាពរបស់សិស្ស និងបុគ្គលិករបស់យើង ខណៈពេលកាត់បន្ថយការរំខានដល់ការអប់រំ។ ដូច្នេះហើយ យើងមានសេចក្តីសោមនស្សរីករាយក្នុងការជំរាបនូវ Swing Space Master Plan (គម្រោងការផ្លាស់ប្តូរទីតាំងសាលាបណ្តោះអាសន្ន) ថ្មីរបស់យើង ដែលត្រូវបានរៀប ចំឡើងដើម្បីជួយសម្រួលមិនឱ្យមានការរំខានដល់ការបង្ហាត់បង្រៀនក្នុងថ្នាក់ផ្ទាល់ នៅពេលចាំបាច់ត្រូវផ្លាស់ប្តូរទីតាំងសិស្សចេញពីសាលារបស់ពួកគេ។

គោលបំណងធំនៃ Swing Space Master Plan (គម្រោងការផ្លាស់ប្តូរទីតាំងសាលាបណ្តោះអាសន្ន) នេះ ត្រូវបានបង្កើតឡើងដើម្បីបង្កើតបរិយាកាសសិក្សាដែលមានសុវត្ថិភាព ដែលអាចបត់បែនបាន និងជម្រើសនៃបរិយាកាសសិក្សាសម្រាប់សិស្សទាំងអស់ នៅពេលមានកាលៈទេសៈដែលមិនអាចប៉ាន់ស្មានបាន ឬមិនអាចគិតទុកជាមុនបាន ប៉ះពាល់ដល់ការសិក្សាធម្មតារបស់ពួកគេ។ ផែនការនេះអនុញ្ញាតឱ្យយើងផ្លាស់ប្តូរទីតាំងសិស្ស និងគ្រូបង្រៀនទៅកាន់ទីតាំងថ្មីបានយ៉ាងឆាប់រហ័ស ដោយធានាថាការអប់រំអាចបន្តបានដោយមានការរំខានតែបន្តិចបន្តួច។

លក្ខណៈសំខាន់ៗនៃផែនការនេះ រួមមាន៖

- **ការឆ្លើយតបយ៉ាងរហ័ស៖** នៅក្នុងព្រឹត្តិការណ៍ដែលមានគ្រោះថ្នាក់ដល់បរិស្ថាន ដូចជា ការសំអាតសារធាតុ អាបេះស្តូស (asbestos) ការសំអាតសារធាតុ ដុះផ្សិត (mold) ការថែទាំអគារ ការជួសជុល ឬការព្រួយបារម្ភអំពីសុវត្ថិភាពផ្សេងទៀត ផែនការនេះអនុញ្ញាតឱ្យយើងផ្លាស់ប្តូរទីតាំងសិស្ស និងបុគ្គលិកទៅកន្លែងបណ្តោះអាសន្នបានយ៉ាងឆាប់រហ័ស ដោយមិនប៉ះពាល់ដល់គុណភាព ឬស្ថិរភាពនៃការអប់រំ។
- **វិធានការសុវត្ថិភាព៖** ទីតាំងបណ្តោះអាសន្ន ត្រូវបានវាយតម្លៃយ៉ាងហ្មត់ចត់ ដើម្បីបំពេញតាមស្តង់ដារសុវត្ថិភាព និងផ្តល់បរិយាកាសសិក្សាដែលមានសុវត្ថិភាព។ អាទិភាពចម្បងរបស់យើងគឺ សុខុមាលភាពរបស់កូនលោកអ្នក ហើយយើងបានចាត់វិធានការប្រុងប្រយ័ត្នគ្រប់បែបយ៉ាងដើម្បីធានាថាកន្លែងបណ្តោះអាសន្នមានសុវត្ថិភាព និងមានអំណោយផលដល់ការសិក្សា។

- **មានការរំខានតែបន្តិចបន្តួច៖** ការផ្លាស់ប្តូរទៅកន្លែងបណ្តោះអាសន្ននឹងត្រូវបានរៀបចំយ៉ាងប្រុងប្រយ័ត្ន ដើម្បីកាត់បន្ថយការរំខានដល់ការសិក្សារបស់កូនលោកអ្នក។ យើងនឹងធ្វើការយ៉ាងជិតស្និទ្ធជាមួយគ្រូ រដ្ឋបាល និងបុគ្គលិកជំនួយការ ដើម្បីរក្សាការបង្ហាត់បង្រៀនជាបន្ត និងផ្តល់ធនធានចាំបាច់។
- **ការប្រាស្រ័យទាក់ទង៖** នៅក្នុងព្រឹត្តិការណ៍នៃការផ្លាស់ប្តូរទៅកាន់កន្លែងបណ្តោះអាសន្ន ការប្រាស្រ័យទាក់ទងទាន់ពេលវេលា និងមានតម្លាភាព គឺជាអាទិភាពរបស់យើង។ យើងនឹងជូនដំណឹងដល់លោកអ្នកគ្រប់ដំណាក់កាល ដោយផ្តល់ព័ត៌មានលម្អិតអំពីដំណើរការផ្លាស់ប្តូរទីតាំង ការរៀបចំយានជំនិះ សេវាអាហារពេលព្រឹក និងអាហារថ្ងៃត្រង់ និងព័ត៌មានបន្ថែមដែលលោកអ្នកត្រូវការ។

យើងដឹងថា ការផ្លាស់ប្តូរបរិយាកាសសិក្សាអាចជាការព្រួយបារម្ភណ៍ ហើយយើងចង់ធានាអះអាងលោកអ្នកថា Swing Space Master Plan (គម្រោងការផ្លាស់ប្តូរទីតាំងសាលាបណ្តោះអាសន្ន) ត្រូវបានបង្កើតឡើងដោយមានការគិតគូរជាទីបំផុតសម្រាប់សុខុមាលភាពរបស់កូនលោកអ្នក។ ការប្តេជ្ញារបស់យើងក្នុងការផ្តល់ការអប់រំដែលមានគុណភាពខ្ពស់នៅតែមិនផ្លាស់ប្តូរ ហើយផែនការនេះគឺជាវិធានការដែលគិតទុកជាមុន ដើម្បីធានាថាការប្តេជ្ញានោះត្រូវប្រកាន់ខ្ជាប់ ទោះបីជាប្រឈមមុខនឹងឧបសគ្គដែលមិនអាចប៉ាន់ស្មានបាន ឬមិនអាចគិតទុកជាមុនបានក៏ដោយ។

ប្រសិនបើលោកអ្នកមានសំណួរ ឬការបារម្ភអ្វីអំពី គម្រោងការផ្លាស់ប្តូរទីតាំងសាលាបណ្តោះអាសន្ន សូមទាក់ទងទៅរដ្ឋបាលសាលារបស់លោកអ្នក ឬអ៊ីមែល facilitiesswingspace@philasd.org។ ដើម្បីស្វែងយល់បន្ថែមអំពីអ្វីៗដែលក្រសួងអប់រំកំពុងធ្វើដើម្បីបង្កើនសុវត្ថិភាពបរិស្ថាន សូមចូលទៅកាន់គេហទំព័ររបស់យើង www.philasd.org/healthyschools។

សូមអរគុណចំពោះការគាំទ្រជាបន្តបន្ទាប់ និងភាពជាដៃគូក្នុងការអប់រំកូនលោកអ្នក។ យើងជឿជាក់ថា គម្រោងការផ្លាស់ប្តូរទីតាំងសាលាបណ្តោះអាសន្ន នឹងបង្កើនសមត្ថភាពរបស់យើងក្នុងការផ្តល់នូវបទពិសោធន៍សិក្សាដែលមានសុវត្ថិភាព និងស្ថិតស្ថេរសម្រាប់សិស្សទាំងអស់ ដើម្បីឱ្យយើងអាចបង្កើនល្បឿន Philly រួមគ្នាជាបន្ត ទោះបីជាមានបញ្ហាអ្វីក៏ដោយ។

ដោយសេចក្តីស្មោះស្ម័គ្រ



Oz Hill
ប្រធាននាយកប្រតិបត្តិ